# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

**ប្រចាំខែ មករា និង កុម្ភៈ ឆ្នាំ ២០១៥/January-February, 2015**

**មាតិកា**


| | ទំព័រ |
|---|---|
| ខ្លឹមសារសង្ខេប/Executive summary | ២ |
| ១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends | ២ |
| ១.១. សន្ទស្សន៍ថ្លៃទំនិញ/Consumer price index | ២ |
| ១.២. វិស័យហិរញ្ញវត្ថុ /Finance | ៤ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trades | ៧ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ៨ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ៩ |
| ១.៦. វិស័យទេសចរណ៍/Tourism | ១០ |
| ១.៧. វិស័យសំណង់/Construction | ១០ |
| ២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ/International commodities price | ១១ |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price average: Brent; Dubai; WTI) | ១១ |
| ២.២. ថ្លៃអង្ករ (Rice price: 5 ភាគរយ; 25 ភាគរយ; 100 ភាគរយ broken) | ១១ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: SGP/MYS; TSR20) | ១១ |
| ៣. ឧបសម្ព័ន្ធ | ១២ |


រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៥

**ប្រធាននាយកដ្ឋានស្ថិតិ**

**ខ្លឹមសារសង្ខេប** (Executive summary)

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញបានកើនឡើង ១,២ ភាគរយ ធៀបនឹងខែកន្លងទៅ ។ តាមការសង្កេត ថ្លៃទំនិញដែលបានកើនឡើងនៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១៥ នេះ គឺដោយសារវិសមភាពនៃការផ្គត់ផ្គង់ និងពីឥទ្ធិពលនៃការកែសម្រួលអត្រាអាករពិសេស ការរឹតបន្តឹងវិធានការរដ្ឋបាលលើការប្រមូលពន្ធ និងការបង្កើនប្រាក់បៀវត្សរ៍ ។ ទន្ទឹមនឹងនេះ ថ្លៃប្រេងនិងវត្ថុធាតុដើមមួយចំនួននៅលើទីផ្សារអន្តរជាតិក៏បានងើបឡើងវិញដែរ ដែលប្រការនេះបានធ្វើឲ្យថ្លៃទំនិញនាំចូលមួយចំនួនដូចជាប្រេងឥន្ធនៈ ជាដើមបានកើនឡើង ។

២. រូបិយវត្ថុ M1 និង M2 មានការកើនឡើងខ្ពស់បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៤ ។ នេះបង្ហាញថា ចរាចររូបិយវត្ថុក្នុងសេដ្ឋកិច្ចកម្ពុជាមានភាពល្អប្រសើរ ពោលគឺមានតម្រូវការសាច់ប្រាក់និងការចាយវាយច្រើននៅក្នុងសេដ្ឋកិច្ច ។ ទន្ទឹមនឹងនេះ ក៏មានការកើនឡើងប្រាក់បញ្ញើរនៅធនាគារដែរ ។ ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជមានការកើនឡើងខ្ពស់ទៅលើវិស័យ សំណង់ ដែលបង្ហាញថាវិស័យនេះកំពុងបន្តកើនឡើងខ្ពស់ ។

៣. សម្រាប់ការនាំចូលក្នុងរយៈពេល២ខែដើមឆ្នាំនេះ បានកើនឡើងខ្ពស់ធៀបទៅនឹងឆ្នាំ ២០១៤ ដែលក្នុងនោះការនាំចូលវត្ថុធាតុដើមវាយនភ័ណ្ឌមានសន្ទុះកើនឡើងខ្លាំងវិញ ដែលបង្ហាញសញ្ញាវិជ្ជមានដល់ផលិតកម្មនៅក្នុងឧស្សាហកម្មកាត់ដេរនៅក្នុងឆ្នាំ ២០១៥ នេះ ។ ដោយឡែកការនាំចេញមានកំណើនទាបជាងឆ្នាំមុនបន្តិចពិសេសគឺការនាំចេញផលិតផលវាយនភ័ណ្ឌ ក៏ប៉ុន្តែការនាំចេញត្រូវបានរំពឹងទុកថានឹងកើនឡើងវិញក្នុងត្រីមាសទី ២ ដោយសារកំណើននៃការនាំចូលវត្ថុធាតុដើមវាយនភ័ណ្ឌ ។

៤. សម្រាប់ការអនុវត្តចំណូលក្នុង២ខែដើមឆ្នាំ ២០១៥ នេះ មានការកើនឡើងខ្ពស់ចំនួន ៨៨ ភាគរយធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ជាពិសេសចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ។ ការអនុវត្តចំណូលនៅក្នុងដើមឆ្នាំនេះមានប្រសិទ្ធភាពខ្ពស់ស្របតាមកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៥. ស្ថានភាពទេសចរណ៍នៅដើមឆ្នាំ ២០១៥ មានការកើនឡើងតិចតួចទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសដោយសារដល់ចុងរដូវកាលទេសចរណ៍ ។

៦. តម្លៃទំនិញនៅលើទីផ្សារអន្តរជាតិមានការប្រែប្រួលបន្តិចនៅខែ កុម្ភៈ ដោយតម្លៃប្រេងឆៅមានការរើបឡើងបន្តិច ស្របពេលដែលតម្លៃអង្ករ និងកៅស៊ូបានធ្លាក់ចុះ ។

## ១. និន្នាការសេដ្ឋកិច្ចកម្ពុជា (Cambodia economic trends)

### ១.១ ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និង សេវាកម្ម (Consumer price index)

តាមប្រភពពីវិទ្យាស្ថានជាតិស្ថិតិបង្ហាញថា នៅខែ កុម្ភៈ ឆ្នាំ ២០១៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញបានកើនឡើង ១,២ ភាគរយ ធៀបនឹងខែកន្លងទៅ ។ តាមការសង្កេត ការកើនឡើងនេះ គឺដោយសារវិសមភាពនៃការផ្គត់ផ្គង់ និងពីឥទ្ធិពលនៃការកែសម្រួលអត្រាអាករពិសេស ការរឹតបន្តឹងវិធានការរដ្ឋបាលលើការប្រមូលពន្ធ និងការបង្កើនប្រាក់បៀវត្សរ៍ ។ ទន្ទឹមនឹងនេះ ថ្លៃប្រេងនិងវត្ថុធាតុដើមមួយចំនួននៅលើទីផ្សារអន្តរជាតិក៏បានងើបឡើងវិញដែរ ដែលប្រការនេះបានធ្វើឲ្យថ្លៃទំនិញនាំចូលមួយចំនួនដូចជាប្រេងឥន្ធនៈជាដើម បានកើនឡើង ។

ក្នុងខែ កុម្ភៈ ឆ្នាំ ២០១៥ សន្ទស្សន៍ថ្លៃម្ហូបអាហារបានកើនឡើង ១,២ ភាគរយ ក្នុងនោះ ថ្លៃសាច់ទាស្រស់បានកើនឡើង ១,៧ ភាគរយ ថ្លៃត្រីស្រស់បានកើនឡើង ១,២ ភាគរយ និងផលិតផលធ្វើពីទឹកដោះគោបានកើនឡើង ១,៨ ភាគរយ ។ សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់បានកើនឡើង ១,៨ ភាគរយ ក្នុងនោះ ស្រាបៀរកើនឡើង ១,៧ ភាគរយ និងថ្នាំជក់បានកើនឡើង ២,០ ភាគរយ ។ សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀតបានកើនឡើង ២,៣ ភាគរយ ក្នុងនោះ ឧស្ម័នបានកើនឡើង ១០ ភាគរយ និងឥន្ធនៈរឹង (ឱស) បានកើនឡើង ៣,៧ ភាគរយ ។

បើធៀបនឹង១២ខែមុន ថ្លៃម្ហូបអាហារនៅតែបន្តកើនឡើងខ្ពស់ ដូចជាថ្លៃសាច់ជ្រូកបានកើនឡើង ៧,៨ ភាគរយ ថ្លៃត្រីស្រស់បានកើនឡើង ៧,២ ភាគរយ ថ្លៃសាច់ទាបានកើនឡើង ៥,៤ ភាគរយ ថ្លៃផ្លែឈើបានកើនឡើង ៧,១ ភាគរយ និងថ្លៃបន្លែបានកើនឡើង ៧,៩ ភាគរយ (សូមមើលតារាង ១.១ ក និង ខ) ។

| តារាង ១.១ ក÷ ការប្រែប្រួលថ្លៃម្ហូបអាហារជាមូលដ្ឋានរយៈពេល ១២ ខែ | | | | |
|---|---|---|---|---|
| **មុខទំនិញ** | **២០១៤** | | **២០១៥** | |
| | **មករា** | **កុម្ភៈ** | **មករា** | **កុម្ភៈ** |
| អង្ករ | ២,៨% | ២,៩% | ០,៨% | ១,២% |
| សាច់គោ | ៩,១% | ៧,៧% | ៣,៤% | ៤,៤% |
| សាច់មាន់ | ៧,១% | ៦,១% | ២,០% | ៣,២% |
| សាច់ទា | ៦,៧% | ៧,៣% | ៣,៥% | ៥,៤% |
| **សាច់ជ្រូក** | **៥,៥%** | **៥,៤%** | **៧,៤%** | **៧,៨%** |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | ៦,៤% | ៥,៩% | ៤,៨% | ៦,៦% |
| ក្នុងនោះត្រីស្រស់ | ៦,៥% | ៦,០% | ៥,៦% | ៧,២% |
| ផ្លែឈើ | ៨,៥% | ៩,៣% | ៤,១% | ៧,១% |
| ផ្លែឈើស្រស់ | ៩,២% | ១០,២% | ៥,២% | ៨,៥% |
| បន្លែ | ៤,៥% | ២,៧% | ៥,៣% | ៧,៩% |
| បន្លែជាស្លឹក | ២,៦% | -០,៥% | ៥,២% | ១០,៨% |
| បន្លែជាផ្លែ | ៦,៣% | ៣,២% | ៨,៥% | ១០,៥% |
| **កំណត់សម្គាល់៖** ប្រភពទិន្នន័យពីវិទ្យាស្ថានជាតិស្ថិតិ | | | | |

| តារាង ១.១ ខ ÷ អតិផរណាប្រចាំឆ្នាំ (%) | | | | | | | |
|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៤ | | | ២០១៥ | | | |
| | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា |
| ប្រទេសកម្ពុជា | 2.90 | 2.40 | 1.10 | 0.40 | 1.60 | 1.50e | - |
| ប្រទេសវៀតណាម | 3.23 | 2.60 | 1.84 | 0.94 | 0.34 | 0.93 | - |
| ប្រទេសថៃ | 1.48 | 1.26 | 0.60 | (0.41) | (0.52) | - | - |
| ប្រទេសម៉ាឡេស៊ី | 2.80 | 3.00 | 2.70 | 1.00 | 0.10 | - | - |
| ប្រទេសឥណ្ឌូនេស៊ី | 4.83 | 6.23 | 8.36 | 6.96 | 6.29 | - | - |
| ប្រទេសភីលីពីន | 4.30 | 3.70 | 2.70 | 2.40 | 2.50 | - | - |
| ប្រទេសចិន | 1.60 | 1.40 | 1.50 | 0.80 | 1.40 | - | - |
| ប្រទេសកូរ៉េខាងត្បូង | 1.20 | 1.00 | 0.80 | 0.80 | 0.50 | - | - |
| ប្រទេសជប៉ុន | 2.90 | 2.40 | 2.40 | 2.40 | 2.20 | - | - |

**កំណត់សម្គាល់៖** ប្រភពទិន្នន័យ(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ (២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com

## ១.២ វិស័យហិរញ្ញវត្ថុ (Finance)

### ១.២.១ រូបិយវត្ថុ

នៅខែ មករា ឆ្នាំ ២០១៥ រូបិយវត្ថុទូទៅ (M2) មានចំនួន ៤៣.៤៩៥ ពាន់លានរៀល កើនឡើង ២,២ ភាគរយ ធៀបនឹងខែមុន និងកើនឡើង ៣០,៦ ភាគរយ ធៀបនឹងឆ្នាំមុន ។ កំណើននេះ បានបំពេញតម្រូវការរូបិយវត្ថុសម្រាប់ផាត់ទាត់ប្រតិបត្តិការសេដ្ឋកិច្ច ។ កំណើនរូបិយវត្ថុទូទៅ (M2) បណ្តាលមកពីសាច់ប្រាក់ប្រើប្រាស់ (M1) កើនឡើង ៤,៤ ភាគរយ ក្នុងនោះរូបិយវត្ថុក្រៅធនាគារកើនឡើង ៥,៧ ភាគរយ និងប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសកើនឡើង ១,៦ ភាគរយ និងប្រាក់បញ្ញើមានកាលកំណត់និងសន្សំបានកើនឡើង ៩,៩ ភាគរយ ដោយឡែកប្រាក់បញ្ញើចរន្តបានថយចុះ ៥,៨ ភាគរយ (សូមមើលតារាង ១.២.១) ។

| តារាង ១.២.១÷ ស្ថានភាពរូបិយវត្ថុ (គិតជាពាន់លានរៀល) | | | |
|---|---|---|---|
| សូចនាកររូបិយវត្ថុ | ២០១៤ | ២០១៥ | បម្រែបម្រួល(%)ធៀបនឹង |
| | ធ្នូ | មករា | ឆ្នាំមុន |
| រូបិយវត្ថុទូទៅ (M2) | 42,560 | 43,495 | 30.6 |
| រូបិយវត្ថុ (M1) | 6,308 | 6,587 | 33.4 |
| រូបិយវត្ថុក្រៅធនាគារ (៛) | 5,593 | 5,913 | 33.0 |
| ប្រាក់បញ្ញើចរន្ត (៛) | 715 | 674 | 37.1 |
| ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ )៛) | 1,090 | 1,198 | 26.3 |
| ប្រាក់បញ្ញើជារូបិយបណ្ណបរទេស | 35,161 | 35,711 | 30.3 |
| *ប្រភព÷ធនាគារជាតិ នៃកម្ពុជា* | | | |

នៅខែ មករា ប្រាក់រៀលដែលចរាចរនៅលើទីផ្សារកើនឡើង ៥,២ ភាគរយ ធៀបទៅនឹងខែមុន ហើយអត្រាសាច់ប្រាក់រៀលធៀបរូបិយវត្ថុទូទៅ (M2) មានចំនួន ១៧,៩ ភាគរយ ។

### ១.២.២. ឥណទាន

ការផ្តល់ឥណទានដោយធនាគារពាណិជ្ជនៅខែ មករា មានកំណើន ៥,៧ ភាគរយ ធៀបនឹងខែមុន និងកើនឡើង ២៤,៩ ភាគរយ ធៀបនឹងខែដូចគ្នាឆ្នាំមុន។ តាមការសង្កេតការផ្តល់ឥណទានដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុបានកើនឡើង ៤,៤ ភាគរយ ធៀបនឹងខែមុន ដោយឥណទាននេះបានគាំទ្រវិស័យសេដ្ឋកិច្ចសំខាន់ៗមួយចំនួន ដូចជាសេវាកម្មបានកើនឡើង ២,៨ ភាគរយ វិស័យឧស្សាហ៍កម្មបានកើនឡើង ២,៧ ភាគរយ វិស័យកសិកម្មកើនឡើង ១៣ ភាគរយ និងវិស័យសំណង់កើនឡើង ៨,២ ភាគរយ ។ បើធៀបនឹងខែដូចគ្នាឆ្នាំមុនការផ្តល់ឥណទានដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុកើនឡើង ២២ ភាគរយ ក្នុងនោះសេវាកម្មកើនឡើង ២១,២ ភាគរយ ឧស្សាហ៍កម្មបានកើនឡើង ៨ ភាគរយ កសិកម្មកើនឡើង ៣៥,១ ភាគរយ និងវិស័យសំណង់កើនឡើង ៣១,៩ ភាគរយ ។

ឥណទានដែលផ្តល់ទៅវិស័យហិរញ្ញវត្ថុមានទំហំ ៧៥៧ ពាន់លានរៀលកើនឡើង ៨,១ ភាគរយ ធៀបនឹងខែមុខ និងកើនឡើង ៥៨ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាពីឆ្នាំមុន ។ សម្រាប់ឥណទានលើតម្រូវការផ្ទាល់ខ្លួនមានការកើនឡើងប្រមាណ ១៤,៥ ភាគរយ ធៀបនឹងខែមុន និងកើនឡើងប្រមាណ ៧១,១ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។

ចំពោះការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅខែ ធ្នូ មានចំនួន ៨.២១៩ ពាន់លានរៀល កើនឡើង ២,៨ ភាគរយ ធៀបនឹងខែមុន និងកើនឡើង ៥៣,២ ភាគរយ ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

### ១.២.៣. អត្រាការប្រាក់

(១) អត្រាការប្រាក់របស់ធនាគារពាណិជ្ជប្រែប្រួលបន្តិចនៅឆ្នាំ ២០១៤ ទាំងអត្រាប្រាក់បញ្ញើនិងប្រាក់កម្ចីជាប្រាក់រៀល និងអត្រាប្រាក់បញ្ញើនិងប្រាក់កម្ចីជាដុល្លារ ប៉ុន្តែ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ អត្រាការប្រាក់របស់ធនាគារពាណិជ្ជមាននិន្នាការថយចុះ (សូមមើលតារាង ១.២.៣.ក) ។

តារាង÷ ១.២.៣.ក. អត្រាការប្រាក់របស់ធនាគារពាណិជ្ជ (គិតជាភាគរយក្នុង១ឆ្នាំ)

| អត្រាការប្រាក់ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ |
| ប្រាក់បញ្ញើជារៀល | 6.58 | 6.16 | 4.91 | 5.80 | 6.02 |
| ប្រាក់កម្ចីជារៀល | 22.49 | 19.35 | 11.79 | 15.72 | 16.26 |
| ប្រាក់បញ្ញើជាដុល្លារ | 4.44 | 4.29 | 3.43 | 4.27 | 4.23 |
| ប្រាក់កម្ចីជាដុល្លារ | 17.15 | 15.36 | 11.61 | 11.35 | 11.51 |

*ប្រភព÷ ធនាគារជាតិ នៃកម្ពុជា*

(២) រយៈពេល១១ខែឆ្នាំ២០១៤ អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការប្រែប្រួលតិចតួច ប៉ុន្តែ អត្រាការប្រាក់បានថយចុះជាបន្តបន្ទាប់ពី ៣៥ ភាគរយ/ឆ្នាំ កាលពីឆ្នាំ ២០១០ មក ៣០ ភាគរយ/ឆ្នាំ នៅឆ្នាំ ២០១៤ (សូមមើលតារាង ១.២.៣.ខ) ។

តារាង÷ ១.២.៣.ខ. អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (គិតជាភាគរយក្នុង១ឆ្នាំ)

| អត្រាការប្រាក់ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|
| | | | | | ធ្នូ |
| គិតជាមធ្យមក្នុងមួយឆ្នាំ | 35.0 | 34.6 | 32.3 | 31.6 | 30.0 |
| គិតជាមធ្យមក្នុងមួយខែ | 2.9 | 2.9 | 2.7 | 2.6 | 2.5 |

*ប្រភព÷ ធនាគារជាតិ នៃកម្ពុជា*

*សំគាល់÷ អត្រាការប្រាក់ឥណទានគិតជាមធ្យមសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗចំនួន ៤ គឺ ហត្ថាកសិករ អម្រឹត ស្ថាបនា និង ប្រាសាក់ ។*

### ១.២.៤ អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារនៅខែ មករា មានចំនួន ៤.០៦០ រៀល/ដុល្លារ ដោយប្រាក់រៀលកើនឡើងតម្លៃបន្តិចធៀបទៅនឹងខែមុន ។ ជាមួយគ្នានេះដែរ នៅខែ មករា ធនាគារជាតិបានទិញប្រាក់ដុល្លារចូលចំនួន

៧៩,៧៣ លានដុល្លារ ។ រីឯ ទុនបម្រុងជារូបិយប័ណ្ណបរទេសសុទ្ធមានចំនួន ៤.៣៦៩ លានដុល្លារ នៅខែ មករា ឆ្នាំ ២០១៥ ។

### ១.៣. **វិស័យពាណិជ្ជកម្ម** (Trades)

**១.៣.១. ការនាំចូល÷** ក្នុងរយៈពេល២ខែដើមឆ្នាំ ២០១៥ នេះការនាំចូលទំនិញមកកម្ពុជាសរុបគិតជាទឹកប្រាក់មានតម្លៃ ១.៧៩២,៦ លានដុល្លារ បានកើនឡើង ២៣,២ ភាគរយ ធៀបទៅនឹងរយៈពេល២ខែដើមឆ្នាំ ២០១៤ ។ សម្រាប់ការនាំចូលទំនិញនៅខែ កុម្ភៈ ទទួលបាន ៩៣៧,៦ លានដុល្លារ កើនឡើងប្រមាណ ៩,៧ ភាគរយ ធៀបទៅនឹងខែមុន។ នៅក្នុងនោះការនាំចូលផលិតផលវាយនភ័ណ្ឌបានកើនឡើង ៥,៩ ភាគរយ ធៀបទៅនឹងខែ មករា កន្លងទៅ ។ ដោយឡែកការនាំចូលយានយន្តបានថយចុះប្រមាណ ១០,៦ ភាគរយ ស្របពេលដែលការនាំចូលប្រេងឥន្ធនៈបានថយចុះ ៣,២ ភាគរយ និងការនាំចូលសភារៈសំណង់ថយចុះ ៤,៩ ភាគរយ ។

បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ ការនាំចូលទំនិញបានកើនឡើងប្រមាណ ៥០,៣ ភាគរយ ដែលក្នុងនោះការនាំចូលផលិផលវាយនភ័ណ្ឌបានកើនឡើង ៨១,៦ ភាគរយ គ្រឿងយន្តកើនឡើង ១៧ ភាគរយ ប្រេងឥន្ធនៈកើនឡើង ១៣ ភាគរយ និងការនាំចូលបរិក្ខាសំណង់បានកើនឡើង ៤,៤ ភាគរយ (សូមមើលតារាង ១.៣.១.)

**តារាង÷ ១.៣.១. តម្លៃទំនិញនាំចូល (ឯកតាជា លានដុល្លា) និង កំណើនជាភាគរយ**

| សូចនាករនាំចូល | ២០១៤ | | ២០១៥ | | | កំណើនជាភាគរយ* | |
|---|---|---|---|---|---|---|---|
| | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | ២ ខែ | កុម្ភៈ | ២ខែ |
| **សរុបតម្លៃនាំចូល** | 934.9 | 958.1 | 855.0 | 937.6 | 1792.6 | *50.3* | *23.2* |
| វាយនភ័ណ្ឌ | 268.7 | 243.7 | 247.0 | 261.7 | 508.7 | *81.6* | *38.4* |
| បរិក្ខាសំណង់ | 27.1 | 33.9 | 34.3 | 32.6 | 66.9 | *4.4* | *3.8* |
| គ្រឿងយន្ត | 79.0 | 75.2 | 74.1 | 66.2 | 140.3 | *17.0* | *22.2* |
| ប្រេងឥន្ធនៈ | 87.3 | 90.8 | 93.7 | 90.7 | 184.4 | *13.0* | *13.1* |
| ផ្សេងៗ | 472.8 | 514.5 | 405.9 | 486.4 | 892.3 | *56.2* | *19.6* |

*ប្រភព÷ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

*សំគាល់÷ *ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន*

**១.៣.២. ការនាំចេញ÷** ក្នុងរយៈពេល២ខែដើមឆ្នាំ ២០១៥ នេះការនាំចេញទំនិញរបស់កម្ពុជាមានតម្លៃជាទឹកប្រាក់ប្រមាណ ១.៤៩៩,៥ លានដុល្លារ បានកើនឡើងប្រមាណ ១៣,៤ ភាគរយធៀបទៅនឹងឆ្នាំ ២០១៤ ។ ក្នុងនោះការនាំចេញនៅក្នុងខែ កុម្ភៈ ទទួលបាន ៦៥១,២ លានដុល្លារ បានថយចុះប្រមាណ ២៣,២ ភាគរយ

ធៀបទៅនឹងខែ មករា ។ ការថយចុះនេះបណ្ដាលមកពីការថយល្បឿននៃការនាំចេញមុខទំនិញសំខាន់មួយចំនួន ដូចជា កៅស៊ូបានថយចុះប្រមាណ ៤៧,២ ភាគរយ ផលិតផលវាយនភ័ណ្ឌបានថយចុះ ២០,៣ ភាគរយ និងការនាំចេអង្ករបានថយចុះប្រមាណ ១៨,៩ ភាគរយ ធៀបទៅនឹងខែ មករា កន្លងទៅ ។

បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៅឆ្នាំមុខ ការនាំចេញទំនិញរបស់កម្ពុជាមានការថយចុះល្បឿន ដោយសារតែការថយចុះនៃការនាំចេញទំនិញសំខាន់ៗ ដូចជា ផលិតផលកាត់ដេរដែលបានថយចុះ ១,៧ ភាគរយ ធៀបទៅនឹងឆ្នាំមុន។ ដោយឡែកមុខទំនិញដទៃទៀតដូចជា កៅស៊ូបានកើនឡើង ៤៦,៨ ភាគរយ អង្ករបានកើនឡើង ៦,៣ ភាគរយ និងផលិតផលផ្សេងៗទៀតបានកើនឡើង ៨,២ ភាគរយ (សូមមើលតារាង ១.៣.២.)។

**តារាង÷ ១.៣.២. តម្លៃទំនិញនាំចេញ (ឯកតាជា លានដុល្លារ) នកំណើនជាភាគរយ**

| សូចនាករនាំចេញ | ២០១៤ | | ២០១៥ | | | កំណើនជាភាគរយ* | |
|---|---|---|---|---|---|---|---|
| | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | ២ ខែ | កុម្ភៈ | ២ខែ |
| **ការនាំចេញសរុប** | 675.2 | 703.0 | 848.3 | 651.2 | 1499.5 | *1.0* | *13.4* |
| ផលិតផលកាត់ដេរ | 445.6 | 504.8 | 605.6 | 482.8 | 1088.5 | *-1.7* | *8.4* |
| អង្ករ | 23.2 | 33.8 | 27.1 | 22.0 | 49.1 | *6.3* | *31.2* |
| កៅស៊ូ | 17.1 | 15.9 | 17.8 | 9.4 | 27.1 | *46.8* | *12.9* |
| ផ្សេងៗ | 189.3 | 148.5 | 197.8 | 137.0 | 334.8 | *8.2* | *30.7* |

*ប្រភព÷ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

*សំគាល់÷ *ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន*

## ១.៤ ស្ថានភាពការអនុវត្តថវិការដ្ឋ (Budget execution)

### ១.៤.១ ការអនុវត្តចំណូល

នៅខែ កុម្ភៈ ឆ្នាំ ២០១៥ រដ្ឋបាលកណ្ដាលចំណូលក្នុងស្រុកអនុវត្តបានចំនួន ១.៣៦៩,៣៦ ពាន់លានរៀល គឺបានកើនឡើង ៨៨,៧ ភាគរយ ធៀបនឹងខែ កុម្ភៈ ឆ្នាំមុន ក្នុងនោះចំណូលពីអគ្គនាយកដ្ឋានពន្ធដារបានកើនឡើង ១៦,៥ ភាគរយ រីឯ អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា បានថយចុះ ៤,៧ ភាគរយ ។

ក្នុងរយៈពេល២ខែដើមឆ្នាំ ២០១៥ ចំណូលក្នុងស្រុកសរុបអនុវត្តបានចំនួន ២.១០៦,១៥ ពាន់លានរៀល គឺ បានកើនឡើង ៥០,១ ភាគរយ បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។

### ១.៤.២ ការអនុវត្តចំណាយ

ក្នុងឆ្នាំ ២០១៤ នេះ ចំណាយសរុបអនុវត្តបានចំនួន ១៣.៣០៦,៥២ ពាន់លានរៀល (ប្រមាណ ១៩,៦៣ ភាគរយនៃ ផសស) គឺបានខ្ពស់ជាង ៣,១៧ ភាគរយ ធៀបទៅនឹងឆ្នាំ ២០១៣ ក្នុងនោះ ចំណាយចរន្តកើនឡើង ៥,៩៥ ភាគរយ ។ ជារួម ចំណាយលើប្រាក់បៀវត្សអនុវត្តបាន ៣.៧៥៥,៤៧ ពាន់លានរៀល មានប្រមាណ ៤៨,៧ ភាគរយ នៃចំណាយចរន្ត

សរុប ឆ្នាំ ២០១៤ បានកើនឡើង ២២,៩ ភាគរយ ធៀបនឹងឆ្នាំ ២០១៤ ឬ ស្មើ ៥,៦ ភាគរយនៃផសស ។ ការកើនឡើងនេះគឺដោយសារ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ ពិសេសលើការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់ អាវុធគ្រប់ប្រភេទ ។ ចំណាយមូលធនអនុវត្តបាន ៥.៥៩០,៧២ ពាន់លានរៀល គឺទាបជាង ០,៤៣ ភាគរយ ធៀបនឹងឆ្នាំ ២០១៣ ក្នុងនោះហិរញ្ញប្បទានក្រៅប្រទេសទទួលបានប្រមាណ ៧៧,១១ ភាគរយ ឬ ថយចុះ ១,០១ ភាគរយ ធៀបឆ្នាំ ២០១៣ ។

### ១.៤.៣ តុល្យភាពថវិកា

នៅឆ្នាំ ២០១៤ អតិរេកចរន្តមានចំនួន ២.៣៣២,៣០ ពាន់លានរៀល គឺបានកើនឡើង ៤០,០៤ ភាគរយ ធៀបឆ្នាំ ២០១៣ ។ កំណើននេះជួយឱ្យរាជរដ្ឋាភិបាលបង្កើនសមត្ថភាពវិនិយោគពីប្រភពថវិកាផ្ទាល់លើវិស័យអទិភាព ពិសេសលើកស្ទួយផលិតភាព និងកំណើនសេដ្ឋកិច្ច បង្កើនការសន្សំដើម្បីទប់ស្កាត់ហានិភ័យនាពេលអនាគត និង គ្រប់គ្រងសេវាបំណុលប្រកបដោយចីរភាព។ តុល្យភាពសរុបមានឱនភាពចំនួន ៣.០៧៤,៤២ ពាន់លានរៀល ។ រាជរដ្ឋាភិបាលបានធ្វើប្រតិបត្តិការហិរញ្ញប្បទានក្រៅប្រទេសចំនួន ៣.៩៧២,០៧ ពាន់លានរៀល ក្នុងនោះមានហិរញ្ញប្បទានសម្រាប់គម្រោងអភិវឌ្ឍន៍ចំនួន ៤.២៦៧,០៨ ពាន់លានរៀល និង សងបំណុលក្រៅប្រទេសមានចំនួន ៣១១,៧៨ ពាន់លានរៀល ។

## ១.៥ ស្ថានភាពវិនិយោគឯកជន (Private investment)

គម្រោងវិនិយោគឯកជនដែលបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានកើនឡើងនៅដើម ឆ្នាំ ២០១៥ ប៉ុន្តែទាបជាងឆ្នាំកន្លងទៅ ។ នៅខែ មីនា ឆ្នាំ ២០១៥ មានចំនួន ២២ គម្រោង គឺកើនឡើង ៦៩,២ ភាគរយ រីឯទុនវិនិយោគមានប្រមាណជា ២.៧៩៥ លានដុល្លារ គឺបានកើនឡើងខ្ពស់ រីឯការបង្កើតការងារបានកើនឡើង ៧៨,៤ ភាគរយ ធៀបនឹងខែមិនាឆ្នាំ ២០១៤ ។

ក្នុងរយៈពេល ៣ខែដើមឆ្នាំនេះ ចំនួនគម្រោងបានថយចុះ ១៤,២ ភាគរយ ប៉ុន្តែចំនួនទុន វិនិយោគមានការកើនឡើងជាពិសេសនៅខែមិនា និង ការបង្កើតការងារក៏មានកំណើនប៉ុន្តែ ក្នុងកម្រិតទាបជាងការរំពឹងទុក (សូមមើលតារាង ១.៥ ) ។

**តារាង ១.៥÷ ស្ថានភាពវិនិយោគឯកជន និង កំណើនជាភាគរយ**

| សូចនាករវិនិយោគ | ឯកតា | ២០១៤ | | | | កំណើនគិតជាភាគរយ (ភាគរយ)* | |
|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | ៣ខែ | មិនា | ៣ខែ |
| ចំនួនគម្រោង | គម្រោង | 10 | 5 | 22 | 37 | 69.2 | -14.2 |
| ចំនួនទុនវិនិយោគ | លាន $ | 62.4 | 16.0 | 2,795 | 2,873 | 1,249.0 | 573.0 |
| ការបង្កើតការងារ | ពាន់នាក់ | 9,711 | 8,343 | 27,508 | 45,562 | 78.4 | 0.2 |

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
*សំគាល់៖ * ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន*

### ១.៦ ស្ថានភាពទេសចរណ៍ (Tourism)

នៅខែ កុម្ភៈ ឆ្នាំ ២០១៥ ចំនួនភ្ញៀវទេសចរណ៍មកដល់កម្ពុជាមានចំនួន ៤៣០,២ ពាន់នាក់ ឬ បានកើនឡើង ១,០ ភាគរយ ធៀបនឹងខែ កុម្ភៈ ឆ្នាំ ២០១៤ ក្នុងនោះ ភ្ញៀវទេសចរធ្វើដំណើរតាមច្រកអាកាសភ្នំពេញបានកើនឡើង ១,៤ ភាគរយ និង ផ្លូវគោកនិងទឹកបានកើនឡើង ១,៨ ភាគរយ រីឯតាមច្រកអាកាសសៀមរាបមិនមានការកើនឡើងទេ ។

ក្នុងរយៈពេល២ខែដើមឆ្នាំនេះ ចំនួនភ្ញៀវទេសចរណ៍សរុបមានចំនួន ៨៩០,៨ ពាន់នាក់ ឬ បានកើនឡើងចំនួន ៤,៦ ភាគរយ (សូមមើលតារាង ១.៦) ។

**តារាង ១.៦÷ ចំនួនភ្ញៀវទេសចរអន្តរជាតិ (ឯកតាគិតជា ពាន់នាក់) និង កំណើនជាភាគរយ**

| សូចនាករសំខាន់ៗ | ២០១៥ | | | កំណើន (ភាគរយ)* | |
|---|---|---|---|---|---|
| | មករា | កុម្ភៈ | ២ខែ | កុម្ភៈ | ២ខែ |
| **ភ្ញៀវទេសចរអន្តរជាតិសរុប** | 442.0 | 430.2 | 890.8 | 1.0 | 2.6 |
| តាមផ្លូវអាកាសច្រកភ្នំពេញ | 84.4 | 84.3 | 178.1 | 1.4 | 6.3 |
| តាមផ្លូវអាកាសច្រកសៀមរាប | 169.5 | 157.4 | 326 | 0.0 | -0.3 |
| តាមផ្លូវគោកនិងទឹក | 188.1 | 188.5 | 386.7 | 1.8 | 3.6 |

*ប្រភព៖ ក្រសួងទេសចរណ៍*
*សំគាល់៖ * ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន*

### ១.៧ ស្ថានភាពសំណង់ (Construction)

ក្នុងរយៈពេល២ខែដើមឆ្នាំ ២០១៥ នេះ គម្រោងសរុបមានចំនួន ២២៥ គម្រោងគឺបានថយចុះ ៣៤,៨ ភាគរយ រីឯផ្ទៃក្រឡាសាងសង់និងទឹកប្រាក់ក៏បានធ្លាក់ចុះ ៨៤,០ ភាគរយ និង ៨៧,២ ភាគរយ រៀងគ្នា ។ តាមការសង្កេត សំណើសាងសង់បានថយនៅដើមឆ្នាំនេះអាចជាសញ្ញាថយល្បឿននៃវិស័យសំណង់ប៉ុន្មានខែខាងមុខ ទោះបីជាសំណើសាងសង់មាននិន្នាការកើនឡើងនៅខែ កុម្ភៈ ក៏ស្ថិតក្នុងកម្រិតទាប ។ (សូមមើលតារាង ១.៧ )

**តារាង ១.៧÷ ស្ថានភាពសំណង់ និង កំណើនជាភាគរយ**

| សូចនាករសំណង់ | ឯកតា | ២០១៥ | | | កំណើន (ភាគរយ)* | |
|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | ២ខែ | កុម្ភៈ | ២ ខែ |
| សរុបចំនួនគម្រោង | គម្រោង | 110 | 115 | 225 | -35.0 | -34.8 |
| សរុបជាផ្ទៃក្រឡា | ពាន់ម$^2$ | 139.2 | 191.6 | 330.8 | -67.4 | -84.0 |
| សរុបជាទឹកប្រាក់ | លានដុល្លារ | 43.4 | 52.8 | 96.2 | -68.5 | -87.2 |

*ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*
*សំគាល់៖ * ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន*

## ២. និន្នាការថ្លៃទំនិញសំខាន់ៗលើពិភពលោក (International commodities price)

**២.១ ថ្លៃប្រេងឆៅ** នៅខែ កុម្ភៈ ឆ្នាំ ២០១៥ តម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (WTI) សម្រាប់កិច្ចសន្យាលក់មួយខែខាងមុខ បានកើនឡើង ៧,០៦ ភាគរយ ធៀបទៅនឹងខែមុន គឺពី ៤៧,២ ដុល្លារ/ធុង ទៅ ៥០,៦ ដុល្លារ/ធុង ។ ចំពោះប្រេងឆៅ (Brent) បានកើនឡើង ២០,៥ ភាគរយ ធៀបទៅនឹងខែមុន គឺពី ៤៨,១ ដុល្លារ/ធុង ទៅ ៥៧,៩ ដុល្លារ/ធុង ។ តាមការសង្កេត ការរើបឡើងបន្តិចក្នុងខែ កុម្ភៈ ឆ្នាំ ២០១៥ នេះ គឺមានន័យថា នៅតែបន្តធ្លាក់ចុះជាមធ្យមប្រមាណ ៣៧ ភាគរយ ធៀបទៅនឹងត្រីមាសមុន ដោយសារកំណើនសេដ្ឋកិច្ចពិភពលោកមានល្បឿនយឺតនិងនៅប្រឈមភាពផុយស្រួយ ។

**២.២ ថ្លៃអង្ករ** នៅខែ កុម្ភៈ ឆ្នាំ ២០១៥ នៅទីក្រុងបាងកកអង្ករនាំចេញ (ខ្ទេច ២៥ ភាគរយ) មានតម្លៃ ៤០០ ដុល្លារ/តោន គឺ ស្ថិតនៅថេរ ធៀបទៅនឹងខែមុនដែលមានតម្លៃ ៤០០ ដុល្លារ/តោន ដូចគ្នា ។ ចំណែកឯនៅប្រទេសវៀតណាមវិញ នៅខែ កុម្ភៈ ឆ្នាំ ២០១៤ អង្ករនាំចេញ (ខ្ទេច ៥ ភាគរយ) មានតម្លៃ ៣៥៣,៥ ដុល្លារ/តោន បានថយចុះប្រមាណ ៥,៥ ភាគរយ ធៀបទៅនឹងខែមុន ។ ទាំងនេះ គឺដោយសារតែតម្រូវការប្រើប្រាស់នៅទាបជាងការផ្គត់ផ្គង់ ជាពិសេសកំណើនស្តុកអង្កររបស់ប្រទេសថៃ ម្យ៉ាងវិញទៀត ក៏ដល់រដូវប្រមូលផលស្រូវប្រាំងផងដែរ ។

**២.៣ ថ្លៃកៅស៊ូ** នៅខែ កុម្ភៈ ឆ្នាំ ២០១៥ កៅស៊ូឆៅស្តង់ដារ TSR 20 មានថ្លៃ ១,៤១ ដុល្លារ/គីឡូ គឺបានថយចុះ ០,៧ ភាគរយ បើប្រៀបធៀបទៅនឹងខែមុន ដែលថ្លៃ ១,៤២ ដុល្លារ/គីឡូ ដោយសាកំណើនផលិតកម្មនៅត្រឹង ជាពិសេសប្រទេសចិនដែលប្រើប្រាស់កៅ (សូមមើលតារាង ២.)

**តារាង÷ ២. ស្ថានភាពថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ**

| សូចនាករសំខាន់ៗ | ឯកតា | ២០១៤ | | ២០១៥ | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|
| | | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | កុម្ភ/កុម្ភៈ ២០១៤ |
| ប្រេងឆៅ (Average) | $/bbl | 76.99 | 60.70 | 47.11 | 54.79 | -47.7 |
| Brent | $/bbl | 78.44 | 62.33 | 48.07 | 57.93 | -46.8 |
| Dubai | $/bbl | 76.73 | 60.52 | 45.98 | 55.83 | -46.8 |
| WTI | $/bbl | 75.81 | 59.26 | 47.27 | 50.61 | -49.8 |
| អង្ករថៃ A.1 (១០០%) | $/mt | 423.80 | 421.18 | 418.55 | 417.00 | -7.3 |
| ថ្លៃអង្ករ (៥%វៀតណាម) | $/mt | 422.00 | 382.39 | 374.42 | 353.50 | -10.1 |
| ថ្លៃអង្ករ (៥%ថៃ) | $/mt | 418.00 | 418.00 | 420.00 | 420.00 | -8.5 |
| ថ្លៃអង្ករ (២៥%ថៃ) | $/mt | 400.00 | 398.00 | 400.00 | 400.00 | 4.7 |
| កៅស៊ូ (TSR20) | $/Kg | 1.54 | 1.48 | 1.42 | 1.41 | -25.0 |
| កៅស៊ូ (SGP/MYS) | $/Kg | 1.64 | 1.60 | 1.65 | 1.81 | -15.7 |

*ប្រភព÷ ធនាគារពិភពលោក, Mekongoryza.com*

********

## ៣. ឧបសម្ព័ន្ធ

### សូចនាករនាំមុខ (Leading Indicators)

**Tourist Arrivals ('000 persons)**




Source: Ministry of Tourism

**Total Textile Export (Mn-US$)**




Source: Customs and Excise Dept.

**Import of Gasoline, Steel, Cement ('000T)**




Source: Customs and Excise Dept.

**Construction Approval in P-Penh (m2)**




Source: Min. LMUC

**Rice Prices in Bangkok and Vietnam 2003 = 100**




Source: MEF & Int.

**Crude oil and Gasoline Price, Jan 2003 = 100**




Source: MEF & Int.

# អតិផរណា និង ទុនបម្រុងបរទេស (Inflation and Foreign Reserves)




Source: NBC




Source: NIS




Source: NIS




Source: NIS




Source: NIS




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)


















# ទិសដៅរូបិយវត្ថុ និងធនាគារ (Money and Banking)

**Liquidity in Bn-R and in % to GDP**




Source: NBC

**NFA and NDA (Bn-R)**




Source: NBC

**Credit to private sector, CPS (Stock) and growth**




Source: NBC

**Credit to Private Sectors by Sector (Bn-R)**




Source: NBC

**Currency outside bank, COB and foreign deposits, FD**




Source: NBC

**MFIs and NGOs Loans Outstanding**




Source: NBC

# ការអនុវត្តថវិកា (Budget)


















# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)

### CDC Approval, Fixed Assets and Growth (Mn. $)




Source: CDC

### CDC Approvals- Fixed Assets by Sectors (Mn. $)




Source: CDC

### Number of Jobs ('000 person)




Source: CDC

### Public Investment by Source of Finance (Bn.R)




Source: MEF

### Net Loans Disbursement (Bn.R)




Source: MEF

### CDC Approvals, Fixed assets by Sources (Mn. $)




Source: CDC

# ទិសស័យពាណិជ្ជកម្ម (Trades)

### Import and Export (mil.US$)




Source: Customs and Excise Department

### Import and Export Growth




Source: Customs and Excise Department

### Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs

### Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF

### Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

### Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

## កំណត់សម្គាល់

កៅស៊ូ÷

- កៅស៊ូ TSR 20 : Technically Specific Rubber ឬហៅបានម្យ៉ាងទៀតថា ISNR 20 : Indian Standards Naturally Rubber ជាប្រភេកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ផលិតជាកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើង អាវភ្លៀជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយស្រួលលាយបញ្ចូលជាមួយសារធាតុដទៃទៀត ដែលធ្វើឱ្យផលិតផលដែលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់ និងមិនងាយសឹងរិចរិល។
- Rubber (Asia), RSS3 Grade, Singapore Commodity Exchange Ltd (SICOM) Nearby Contract Beginning 2004; During 2000 To 2003, Singapore RSS1; Previously Malaysia RSS1 [RUBBER1_MYSG] **UNITS:** ($/kg) | **SOURCE:** Singapore Exchange Ltd (SGX Previously SICOM); Bloomberg; Rubber Association Of Singapore Commodity Exchange (RASCE); International Rubber Study Group; Asian Wall Street Journal; World Bank.
- RSS 3 : Ribbed Smoked Sheets ជាប្រភេទកៅស៊ូដែលចំរាញ់ចេញពីដើមដែលមានគុណភាពខ្ពស់។ កៅស៊ូប្រភេទនេះត្រូវបានកែច្នៃហើយមានទ្រង់ទ្រាយជា សន្លឹក និងជាដុំស្ងួត។ RSS 3 ប្រើប្រាស់សម្រាប់ផលិតជា កង់រថយន្ត និងបំពង់ទីបជ័រ និងស្បែកជើង។ ជាទូទៅវាត្រូវបានគេប្រើប្រាស់ច្រើននៅក្នុងឧស្សាហ៍កម្មផលិតសំបកកង់រថយន្ត ហើយជាង ៥០ភាគរយ នៃផ្នែកសំខាន់របស់ផលិតផលត្រូវបានផលិតពីកៅស៊ូនេះ។

ប្រេងឆៅ÷

ប្រេងឆៅដែលបានបង្ហាញក្នុងតារាង ២.០ ជាប្រភេទប្រេងឆៅធនស្រាន (Light Crude Oil) ដែលគេធ្វើការទិញលក់ជាលក្ខណៈកិច្ចសន្យាអនាគត (Future Contract) ។ ប្រេងឆៅនៅក្នុងទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នាទៅតាមប្រភេទដូចជា÷ WTI (West Texas Intermediate) ប្រភេទប្រេងរបស់អាមេរិក, Brent ប្រភេទប្រេងរបស់ អង់គ្លេស និង Dubai ជាប្រភេទប្រេងរបស់ប្រទេសអារ៉ាប់ប៊ីសាអ៊ូឌីត។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈខុសគ្នាទៅតាម កម្រិតភាព ស្រាលហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេ អាចចំរាញ់ ចេញជាប្រេងឥន្ធៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់ក្នុងការវាស់វែងភាពស្រាលនៃប្រភេទ ប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែល មានកម្រិត API Gravity កាន់តែខ្ពស់ គឺជាប្រភេទប្រេងដែល កាន់តែស្រាល និងអាចចំរាញ់ចេញជាប្រេងឥន្ធនៈបានច្រើន។

- WTI 40$^{o}$ API
- Brent 38$^{o}$ API
- Dubai 32$^{o}$ API

# និន្នាការសេដ្ឋកិច្ចសង្គម

## **Socio-Economic Trends**

**ប្រចាំខែ មករា/កុម្ភៈ ឆ្នាំ ២០១៥/January-February, 2015**

*រៀបចំដោយ*

*នាយកដ្ឋានស្ថិតិ*

*អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ*

*ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

*Statistics Department*

*General Department of Economic and Public Finance Policy*

*Ministry of Economy and Finance*

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*១ លោក ឆូវ សុមេធា*

*២ លោក សុខ ខន*

*៣ លោក ហាក់ សុផល*

*ម៉ោងធ្វើការ៖ ៧:០០ ដល់ ១១:០០ ព្រឹក*

*២:០០ ដល់ ៥:០០ រសៀល*

*ទូរស័ព្ទលេខ៖ ០២៣ ៤២៧ ៩១៣*